# មានបញ្ហានៅសួនឧទ្យាន

ហាន់ជើ បានដកដង្ហើមធំ ។ « ខ្ញុំមិននិយាយពាក្យសម្ដីទាំងនោះទេ » ។



ដោយ ដាយអាណា អឺវលីន ណិលសុន
( ផ្អែកទៅលើដំណើររឿងពិត )

*ដំណើររឿងនេះបានកើតឡើងនៅ ស.រ.អា.* ។

ហាន់ជើ បានរត់កាត់សួនជាមួយមិត្តភក្ដិរបស់គាត់ ។ គាត់បានញញឹមនៅពេលគាត់មានអារម្មណ៍ថាខ្យល់បក់ប៉ះមុខគាត់ ។ គាត់មានអារម្មណ៍ថាពេលវេលាកន្លងទៅលឿនហើយធូរស្រាល !

ខាយល៍បានប៉ះរបងមុន ។ គាត់បានស្រែកថា « ខ្ញុំឈ្នះហើយ ! » ។

ហាន់ជើ បានរត់ទៅដល់របងមួយសន្ទុះក្រោយមក ។ « មិនយុត្តិធម៌ទេ ! ឯងចាប់ផ្ដើមមុន » ។

មីហ្គែល បានតបថា « មែនហើយ » ។ « តោះរត់ប្រណាំងទៅដើមឈើ ! »

ហាន់ជើ បានចាប់ផ្ដើមរត់ម្ដងទៀត ។ ពេលនេះគាត់បានរត់ទៅប៉ះដើមឈើមុន ។ ប៉ុន្តែ មីហ្គែល នៅពីក្រោយគាត់ជាប់ ។

មីហ្គែល បាននិយាយថា « ខ្ញុំឈ្នះហើយ » ។

ផែបភើ និយាយថា « ទេ ហាន់ជើ ឈ្នះ » ។

ខាយល៍ បាននិយាយថា « មែនហើយ » ។



មីហ្គែល បានឱបដៃគាត់ ។ បន្ទាប់មកគាត់ប្រើពាក្យសម្ដីមិនល្អ ។

ក្មេងដទៃទៀតបានសើច ។ មីហ្គែល បាននិយាយពាក្យនេះម្ដងទៀត ហើយពួកគេបានសើចបន្តទៀត ។

ហាន់ជើ មានអារម្មណ៍សោកសៅក្នុងចិត្ត ។ គាត់បានដឹងថាពាក្យសម្ដីទាំងនោះមិនល្អទេ ។ ប៉ុន្តែគាត់មិនចង់អោយគេសើចចំអកទេ ។ តែគាត់មិនបាននិយាយអ្វីទាំងអស់ ។

ផែបភើ បាននិយាយពាក្យសម្ដីអាក្រក់មួយផ្សេងទៀត ។ បន្ទាប់មកខាយល៍ បាននិយាយពាក្យអាក្រក់មួយទៀត ។

ខាយល៍ បាននិយាយថា « ឥឡូវនេះឯងនិយាយម្ដងទៅ ហាន់ជើ » ។

មីហ្គែល បាននិយាយ « មែនហើយនិយាយទៅ » ។ « និយាយពាក្យដើថ្មីមួយទៅ » ។

ហាន់ជើ បានដកដង្ហើមធំ ។ « ខ្ញុំមិននិយាយពាក្យសម្ដីទាំងនោះទេ » ។

ខាយល៍ បាននិយាយថា « គ្រាន់តែនិយាយពាក្យមួយម៉ាត់វាមិនធ្វើឲ្យឈឺចាប់ទេ » ។

ហាន់ជើ បាននិយាយថា « ខ្ញុំមិនប្រើពាក្យទាំងនោះទេ » ។

« តើឯងខ្លាចមែនទេ ? » មីហ្គែល បានសើច ។

មុខរបស់ ហាន់ជើ ឡើងក្រហម ។ « ខ្ញុំនឹងទៅលេងកន្លែងផ្សេងទៀត » ។

ក្មេងៗដែលនៅសល់ទាំងប៉ុន្មានបានសើច ហើយនិយាយពាក្យសម្ដីអាក្រក់ៗទៀត ។ ហាន់ជើ ចង់រត់ចេញ ។ ឥឡូវនេះសួនឧទ្យាននេះមិនធ្វើឲ្យមានអារម្មណ៍សប្បាយទេ ។ គាត់បាននិយាយដោយរាបសាថា « ជួបគ្នាពេលក្រោយ » ។

ហាន់ជើ លូកដៃដាក់ចូលក្នុងហោប៉ៅរបស់គាត់ ហើយបានដើរកាត់ក្មេងៗទាំងនោះយឺតៗ ។ គាត់មិនមានអារម្មណ៍ថាពេលវេលាកន្លងទៅលឿន ហើយធូរស្រាលទៀតទេ ! គាត់មានអារម្មណ៍ថាមានសម្ពាធ ។

គាត់បានរត់ទៅរកប៉ា និងម៉ាក់របស់គាត់នៅលើកៅអី ។ ប៉ាបានដាក់សៀវភៅរបស់គាត់ចុះ ។ « កូនមិនអីទេ មែនទេ ? »

ហាន់ជើ បានញាក់ស្មា ។ « ពួកគេចាប់ផ្ដើមនិយាយពាក្យអាក្រក់ៗ ។ ខ្ញុំមិនចង់និយាយអីចឹងទេ ដូច្នេះខ្ញុំក៏បានចាកចេញទៅ » ។

ម៉ាក់បានញញឹម ។ « កូនក្លាហានណាស់ » ។

ប៉ាបានតបថា « ប៉ាម៉ាក់មានមោទនភាពចំពោះកូនណាស់ » ។ « វាពិបាកក្នុងការធ្វើការជ្រើសរើសល្អ នៅពេលដែលមនុស្សនៅជុំវិញខ្លួនយើងមិនល្អ » ។

ហាន់ជើ បានដកដង្ហើមធំ ។ គាត់សប្បាយចិត្តដែលគាត់បានជ្រើសរើសត្រឹមត្រូវ ប៉ុន្តែគាត់នៅតែមានអារម្មណ៍មិនល្អទេ ។

ម៉ាក់បានសួរ « តើកូនចង់ទៅផ្ទះមែនទេ ? »

ហាន់ជើ បានគិតអំពីរឿងនោះ ។ គាត់បាននិយាយថា ៖ « មិនទាន់ចង់ទៅទេម៉ាក់ » ។ គាត់បានសម្លឹងមើលទៅក្រុមក្មេងៗមួយក្រុមផ្សេងទៀត ដែលកំពុងលេងទោងខ្សែកាប ។ « កូនចង់ទៅលេងទីនោះ » ។

នៅពេលដែល ហាន់ជើ បានដើរទៅ ក្មេងប្រុសម្នាក់បានលើកដៃគ្រវីរកគាត់ ។ « សួស្ដី ខ្ញុំឈ្មោះដេវីឌ » ។

« ខ្ញុំឈ្មោះ ហាន់ជើ ។ តើខ្ញុំអាចលោតលេងជាមួយឯងបានទេ ? »

« ប្រាកដជាបាន ! »

ហាន់ជើ បានដាក់វេនគ្នាជិះទោងខ្សែកាប ហើយមានអារម្មណ៍ថាមានខ្យល់បក់ប៉ះគាត់យ៉ាងខ្លាំង ។ នៅពេលគាត់លេងជាមួយដេវីឌ និងអ្នកផ្សេងទៀតគាត់មានអារម្មណ៍ថាពេលវេលាកន្លងទៅលឿន និងបានធូរស្រាលម្ដងទៀត ។ គាត់បានធ្វើអ្វីដែលត្រឹមត្រូវទោះបីជាវាពិបាកក៏ដោយ ។ គាត់សប្បាយចិត្តដែលគាត់បានធ្វើការជ្រើសរើសត្រឹមត្រូវ ។ ●

ដើម្បីរៀនបន្ថែមអំពីការធ្វើការជ្រើសរើសត្រឹមត្រូវ សូមអានបទដ្ឋានដំណឹងល្អរបស់ខ្ញុំនៅខាងក្រោយ *សៀវភៅណែនាំកុមារ* របស់ប្អូនៗ ។